# ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ និងលោកជំទាវ អញ្ជើញជាអធិបតីក្នុងកម្មវិធីសម្ពោធអាគារតាំងបង្ហាញរថយន្ត Volkswagen នៅរាជធានីភ្នំពេញ




នាយប់ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧៖ ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្មបានឲ្យដឹងថា ប្រទេសកម្ពុជាជាប្រទេសមួយដែលមានសក្តានុពលខ្ពស់ ប្រសិនបើកម្ពុជាមិនមែនជាប្រទេសដែលមានសក្តានុពលផ្នែកសេដ្ឋកិច្ចនោះទេ ប្រហែលជាមិនមែនប្រទេសដទៃណាមកវិនិយោគនៅក្នុងប្រទេសកម្ពុជានោះឡើយ។



ឯកឧត្តមទេសរដ្ឋមន្ត្រីបានថ្លែងថា **«កម្ពុជាពិតជាប្រទេសដែលមានសក្តានុពលពិតមែន បើកម្ពុជាមិនមានសក្តានុពលអភិវឌ្ឍសេដ្ឋកិច្ចទេ គេក៏មិនមកវិនិយោគជាមួយដែរ។ បើមិនមានថ្នាក់វណ្ណៈកណ្តាលដែលមានលុយអាចទិញរបស់ទំនើបៗទេនោះ»**។

ឯកឧត្តមទេសរដ្ឋមន្ត្រីបានបន្តថា នេះមិនមែនជារឿងចម្លែកទេដែលប្រទេសដទៃទៀត មកវិនិយោគចាប់ដៃគូជាមួយអ្នកវិនិយោគិននៅកម្ពុជា ព្រោះគេឃើញថាស្នាដៃរបស់ អ្នកវិនិយោគិនកម្ពុជាដែលបានធ្វើកន្លងមក មានជាមួយក្រុមហ៊ុនល្បីៗជាច្រើនមានភាពល្អប្រសើរ និងទទួលបានជោគជ័យទាំងការទាក់ទាញម៉ាកល្បីៗ ដូចជាម៉ាកម្ហូបអាហារ ភោជនីយដ្ឋាន គ្រឿងសំភារៈផ្សេងៗមកកម្ពុជា **«អ្នកវិនិយោគិនបរទេសទាំងអស់មានភាពជឿជាក់លើអ្នកវិនិយោគិនកម្ពុជា ហេតុដូច្នេះទើបក្រុមហ៊ុន Volkswagen មកចូលរួមសហការដើម្បីសម្ពោធអគារតាំងបង្ហាញរថយន្តនេះ។ ខ្ញុំសូមកោតសសើរដោយស្មោះស្ម័គ្រចំពោះលោកលោកស្រី អ្នកនាងកញ្ញាទាំងអស់ដែលបានខិតខំ ទាក់ទាញម៉ាកល្អៗពីបរទេសមកកម្ពុជា»**។

ប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រទេសកម្ពុជាបានបន្តដំណើរឆ្ពោះទៅផ្នែកមួយដ៏សំខាន់ ក្នុងសហគមន៍អាស៊ានដោយមានកំណើនសេដ្ឋកិច្ចថេរ មានស្ថេរភាពនយោបាយល្អ និងផ្តោតសំខាន់ លើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ ទាំងនេះបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ ពីលំហូរចូលនៃវិនិយោគទុនបរទេសដែលមិនចេះរីងស្ងួតចូលក្នុងប្រទេស និងការកើនឡើងនូវចំនួនម៉ាកផលិតផលអន្តរជាតិ ដែលបាននាំចូលដោយក្រុមហ៊ុនក្នុងស្រុក។




សូមបញ្ជាក់ថា ក្រុមហ៊ុនផលិតរថយន្តអាល្លឺម៉ង់ Volkswagen បានសហការជាមួយក្រុមហ៊ុន HGB Group Co. Ltd រៀបចំសម្ពោធអគារតាំងលក់រថយន្ត ប្រណីត និងទំនើបកម្រិតខ្ពស់

របស់ខ្លួនហើយកាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧។ ភាពជាដៃគូនេះ ក្រុមហ៊ុន HGB Group នឹងក្លាយទៅជាតំណាងចែកចាយតែមួយគត់ដែលមានលក់រថយន្តតូចៗសម្រាប់គ្រួសារ និបប្រភេទរថយន្ត ដឹកអ្នកដំណើរសម្រាប់អាជីវកម្ម របស់ក្រុមហ៊ុន Volkswagen។




អាគារថ្មីនេះផ្តោតសំខាន់លើការលក់រថយន្ត ការផ្តល់សេវាកម្មហ័សទាន់ចិត្ត និងគ្រឿងបន្លាស់សម្បូរបែប នៅទីនោះជាកន្លែងតែមួយគត់ដែលមានបំពាក់បច្ចេកទេសទំនើបបំផុត និងជាកន្លែងផ្តល់ប្រឹក្សាយោបល់ក្រោយការលក់ដ៏ល្អបំផុត ដែលមានបុគ្គលិកដែលទទួល ការបណ្តុះបណ្តាលនូវចំណេះជំនាញច្បាស់លាស់។

សូមជម្រាបថា ក្រុមហ៊ុន HGB Group ជាក្រុមហ៊ុនឯកជនក្នុងស្រុកមួយរបស់កម្ពុជា ដែលមានឯកទេសលើវិស័យយានយន្តគ្រប់ជុន F&B ការរលក់រាយ និងលក់ទំនិញប្រណីត ហើយបានក្លាយទៅជាក្រុមហ៊ុន ចែកចាយស្រប់ច្បាប់រថយន្តម៉ាក Volkswagen នៅកម្ពុជា។